00380688

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៩

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 29 / 09 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកឧត្តម ស៊ឹម កា
សមាជិកព្រឹទ្ធសភា
[redacted]

ឯកឧត្តមជាទីគោរព

នៅក្នុងក្របខណ្ឌនៃកិច្ចស៊ើបសួរដែលកំពុងដំណើរការប្រឆាំងនឹង នួន ជា អៀង សារី ខៀវ សំផន និងជនដទៃទៀត អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដោយបានឃើញជាអាទិ៍ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈទាំងឡាយពីមុនរបស់ឯកឧត្តម (ជាពិសេស សេចក្តីថ្លែងការណ៍ដែលឯកឧត្តមបានយល់ព្រមធ្វើជាមួយអ្នកស្រាវជ្រាវម្នាក់ នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ ១៩៩០) យើង ត្រូវរៀបចំឱ្យមានការស្តាប់យកចម្លើយរបស់ឯកឧត្តមក្នុងនាមជាសាក្សី។

កិច្ចស៊ើបសួរនេះ ត្រូវតែរៀបចំឡើងដោយគោរពតាមបែបបទនីតិវិធីដែលតម្រូវចំពោះសហចៅក្រមស៊ើបអង្កេត (បានន័យថា ធ្វើឡើងនៅក្នុងបរិវេណនៃ អ.វ.ត.ក. និង ជាសម្ងាត់)។ នៅក្នុងគោលបំណងនេះ ឯកឧត្តម អាចឃើញមានភ្ជាប់មកជាមួយនេះនូវដីកាកោះអញ្ជើញសាក្សីផ្លូវការមួយច្បាប់។ ខ្ញុំ សូមបញ្ជាក់ថា

A297

កាលបរិច្ឆេទដែលបានដាក់នៅក្នុងដីកានេះ គ្រាន់តែជាកាលបរិច្ឆេទបឋមប៉ុណ្ណោះ។ ក្នុងករណីដែលឯកឧត្តមមានធុរៈមិនអាចដកឃ្លាពីការងាររបស់ឯកឧត្តមបាននាកាលបរិច្ឆេទបឋមដែលបានកំណត់ខាងលើ ខ្ញុំ សូមឯកឧត្តមទំនាក់ទំនងជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងពេលឆាប់ៗនេះ ដើម្បីកំណត់យកកាលបរិច្ឆេទណាមួយទៀត។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

**សហចៅក្រមស៊ើបអង្កេត**

Marcel Lemonde